## សេចក្តីលម្អិតរបស់អង្គការ AHHA

អង្គការ ការអប់រំ AHHA  គឺជាអង្គការអន្តរជាតិមួយដែលផ្តល់នូវកម្មវិធីដែលទទួលបានពានរង្វាន់ក្នុងការអភិវឌ្ឍន៍សក្តានុពលរបស់មនុស្ស។

ការរីកចម្រើនរបស់អង្គការ ការអប់រំ AHHA ចាប់តាំងពីឆ្នាំ២០០០ មក ហើយបានបង្កើតនូវប្រព័ន្ធអ៊ីកូឡូស៊ីសម្រាប់ឱកាសនៃការអប់រំដល់មនុស្សជាច្រើននាក់។

### ទស្សនៈវិស័យរបស់យើង

ទស្សនៈវិស័យរបស់យើងគឺមនុស្សម្នាក់ៗដែលយើងអាចជួយគាត់បាន នឹងយល់អំពីគោលបំណងដែលគាត់បានកើតមកក្នុងលោកនេះ ហើយយើងមានឧបករណ៍ក៏ដូចជាកន្លែងសម្រាប់អភិវឌ្ឍសក្តានុពលរបស់គាត់ ក្នុងវិធីសាស្រ្តមួយពិតប្រាកដនិងពេញលេញ។

### បេសកកម្មរបស់យើង

បេសកកម្មរបស់យើងគឺផ្តល់ឲ្យអ្នកគ្មានឱកាស និងការអប់រំ នូវគុណភាពនៃការអប់រំប្រកបដោយ ភាពពិតប្រាកដ ការអនុវត្តន៍ផ្ទាល់ និងពេញលេញ។



# លទ្ធផល

បានបង្រៀនសិស្សជាង

បង្រៀនសិស្សជាង 10,000 នាក់ប្រចាំថ្ងៃ

បានហ្វឹកហ្វឺនគ្រូសាលារដ្ឋចំនួន400នាក់

បង្រៀនភាសាអង់គ្លេសទៅសាលារដ្ឋចំនួន 30

99 % នៃសិស្សបញ្ចប់ការសិក្សាទទួលបានការងារធ្វើ

150 centers since 2000

កម្មវិធីផ្លាស់ប្តូរបទពិសោធន៍សម្រាប់សិស្ស 200 នាក់នៅបរទេស

បានធ្វើសកម្មភាពក្នុង 7 មជ្ឈមណ្ឌលទូទាំងប្រទេស

### សូមទំនាក់ទំនងមកយើងតាមរយៈ:

www.ahhaeducation.org

+855 12 619 719

cd.singh.ahhaeducation@gmail.com

អាសយដ្ឋានៈ ភូមិមិត្តភាព១ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កម្ពុជា

## អង្គការ ការអប់រំ AHHA

AHHA Education CAMBODIA



“ គ្រូធម្មតាម្នាក់ទទួលនិច្ឆ័យលើសិស្ស គ្រូធ្វើមម្នាក់អប់រំសិស្ស“

# កម្មវិធីការអប់រំទាំង ៩



## កម្មវិធីសម្រាប់សិស្សសិក្សានិងស្នាក់នៅ

### កម្មវិធីសម្រាប់សិស្សសិក្សានិងស្នាក់នៅរយៈពេល ២០ ខែ

យុវជនអាយុចាប់ពី១៦ឆ្នាំដល់២៩ឆ្នាំឆ្លងកាត់ការអប់រំរយៈពេល២០ខែលើការហ្វឹកហ្វឺនជំនាញការងារនិងបំណិនជីវិត។ សិស្សានុសិស្សសិក្សាប្រធានបទដូចជា៖ ភាសា ព័ត៌មានវិទ្យា ភាពជាអ្នកដឹកនាំ ការបង្រៀន ការគ្រប់គ្រងគណនេយ្យ ។ល។ ក្នុងការអនុវត្តន៍ជាក់ស្តែងសិស្សទាំងអស់ក្លាយជាគ្រូបង្រៀន អ្នកជំនួយការ និងការកាន់កាប់លើតួនាទីផ្សេងៗជាច្រើន

### កម្មវិធីផ្ទះទីពីរ

កម្មវិធីផ្ទះទីពីរផ្តល់ដំណោះស្រាយដល់សិស្សកម្ពុជាជាច្រើនដែលខ្វះខាតសាលារៀនដោយការផ្តល់កន្លែងស្នាក់នៅក្នុងមជ្ឈមណ្ឌលយើងហើយពួកគេអាចទៅសាលារដ្ឋដែលនៅជិតនិងចូលរួមកម្មវិធីអប់រំរបស់សាលាយើងក្នុពេលតែមួយ។

### *កម្មវិធីសម្រាប់វិស្សមកាល ៣ខែ*

កម្មវិធីសម្រាប់វិស្សមកាល ៣ខែគឺអនុញ្ញាតឲ្យសិស្សរាល់គ្នាដែលចង់មកសិក្សាកំឡុងវិស្សមកាល ។ កម្មវិធីនេះគឺស្រដៀងទៅនិងកម្មវិធី ២០ខែ ក្នុងឆមាសទី ២។

## កម្មវិធីដែលមិនតម្រូវឲ្យសិស្សសិក្សានិងស្នាក់នៅ

### ថ្នាក់សិក្សាដែលបង់កម្រៃសិក្សាតិចតួច

ថ្នាក់សិក្សាដែលបង់កម្រៃសិក្សាតិចតួចត្រូវបានផ្តល់សេវាកម្មក្នុងសាលារបស់យើង។ យើងផ្តល់ការអប់រំលើភាសាអង់គ្លេសនិងកុំព្យូទ័រប្រកបដោយគុណភាព។ វគ្គសិក្សានេះគឺសម្រាប់សិស្សសាលា សិស្សសកលវិទ្យាល័យ បុគ្គលិកក្រុមហ៊ុនដែលចង់រៀនភាសាអង់គ្លេសឬកុំព្យូទ័រ។

### ថ្នាក់សិក្សាដោយឥតគិតថ្លៃសម្រាប់កុមារប្រចាំថ្ងៃ

ថ្នាក់សិក្សាដោយឥតគិតថ្លៃរបស់អង្គការ ការអប់រំAHHA កម្ពុជាបង្រៀនសិស្ស ភាសាអង់គ្លេស ភាពច្នៃប្រឌិត មេត្តាករុណាធម៌ ហើយនិងតម្លៃសីលធម៌ក្រោមរូបភាពរីករាយ។

ក្មេងៗសិក្សាតាមរយៈការប្រាស្រ័យទាក់ទង់គ្នារវាងមិត្តភក្តិតូច និងធំជាច្រើនដែលជួយឲ្យពួកគេអភិវឌ្ឍជំនាញសង្គម តាំងពីតូច។ ថ្នាក់រៀនរបស់យើងផ្តោតទៅលើការអភិវឌ្ឍន៍មូលដ្ឋានគ្រិះនៃអត្តចរិតដ៏រឹងមាំនិងការអភិវឌ្ឍន៍សក្តានុពលរបស់ពួកគេ។

### *កម្មវិធីសិក្សាជាមួយដៃគូអភិវឌ្ឍប្រចាំថ្ងៃ*

កម្មវិធីសិក្សាជាមួយដៃគូរបស់យើងគឺជាដៃគូរវាងសាលាអប់រំ AHHA កម្ពុជានិងសាលាបឋមសិក្សា អនុវិទ្យាល័យ វត្តអារាម មន្ទីរពេទ្យ ពន្ធនាគារ ឬកន្លែងផ្សេងៗដែលត្រូវការការអប់រំ។ យើងផ្តល់កម្មវិធីអប់រំរបស់យើង(ជាចម្បងភាសាអង់គ្លេស) រយៈពេល១ម៉ោងទៅ២ម៉ោងក្នុងមួយថ្ងៃ។ ថ្នាក់សិក្សាគឺឥតគិតថ្លៃ ហើយសិស្សានុសិស្សរីករាយនិងការជួយបន្ថែមដែលពួកគេបានទទួលពីកម្មវិធីរបស់យើង។

## កម្មវិធីផ្ទេរជំនាញវិជ្ជាជីវៈ

### កម្មវិធីសម្រាប់ពលរដ្ឋល្អ

កម្មវិធីនេះគឺជំហ៊ានដំបូងបង្កើនសមត្ថភាពឲ្យក្លាយជាគ្រូម្នាក់ដែលមានបទពិសោធន៍ អ្នកគ្រប់គ្រង និងអ្នកដឹកនាំក្នុងវិស័យសេវាសង្គមនិងការអភិវឌ្ឍន៍សហគមន៍។ សិស្សានុសិស្សក្នុងកម្មវិធីនេះចាប់យកនូវតួនាទីជាគ្រូបង្រៀន ឬកាន់កាប់លើកិច្ចការក្នុងសាលាផ្ទះបាយក្នុងសាលា ការរៀបចំសាលានិងកិច្ចការផ្សេងៗទៀត។

### កម្មវិធីការនាំយកនូវបទពិសោធន៍មកវិញ

អ្នកស្ម័គ្រចិត្តឆ្នើមៗដកបទពិសោធន៍២ឆ្នាំនៅប្រទេសក្រៅនៅក្នុងសាខាក្រៅប្រទេសរបស់យើងដូចជា៖ ប្រទេសឡាវ ឬប្រទេសទីម័រ។ បន្ទាប់ពីទទួលបានបទពិសោធន៍និងការអភិវឌ្ឍន៍ជំនាញជាច្រើន អ្នកស្ម័គ្រចិត្តទាំងអស់ត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីធ្វើការផ្ទេរចំណេះដឹងនិងជំនាញដែលទទួលបានទៅយុវជនខ្មែររយៈពេល៦ខែ។

### កម្មវិធីការផ្ទេរភាពជាអ្នកដឹកនាំ

អ្នកស្ម័គ្រចិត្តនឹងអនុវត្តជំនាញទាំងនេះដោយគ្រប់គ្រងមជ្ឈមណ្ឌលនៅតាមខេត្តក្រោមការត្រួតពិនិត្យពីថ្នាក់ដឹកនាំរបស់អង្គការការអប់រំ AHHA។ នៅពេលដែលពួកគេបានអភិវឌ្ឍគ្រប់ជំនាញទាំងអស់ពួកគេអាចធ្វើសេវាកម្មសង្គមដោយខ្លួនរបស់ពួកគេផ្ទាល់ ហើយយើងនឹងផ្ទេរកម្មសិទ្ធទៅឲ្យអ្នកគ្រប់គ្រងទាំងអស់ដើម្បីឲ្យពួកគេអាចបន្តដំណើរការនៃមជ្ឈមណ្ឌលដោយឯករាជ។

